International Labour Organization

**ការកសាងភាពធន់ក្នុងកំឡុងពេល និងក្រោយការរាតត្បាតនៃមេរោគកូវីដ-១៩**

គោលការណ៍ណែនាំអំពីកូវីដ-១៩ និងបញ្ជីសកម្មភាព

សម្រាប់រោងចក្រកាត់ដេរ និងអ្នកគ្រប់គ្រង



# គោលការណ៍ណែនាំសម្រាប់រោងចក្រកាត់ដេរដើម្បីកសាងភាពធន់ក្នុងកំឡុងពេល និងក្រោយការរាតត្បាតនៃមេរោគកូវីដ-១៩

អង្គការអន្តរជាតិខាងការងារបានបង្កើតគោលការណ៍ណែនាំចំនួន ៦ ដែលផ្តោតលើសកម្មភាពសម្រាប់រោងចក្រកាត់ដេរនៅទ្វីបអាស៊ី ដើម្បីឱ្យពួកគេដោះស្រាយវិបត្តិនៃជំងឺកូវីដ-១៩ និងដើម្បីកសាងភាពធន់របស់អាជីវកម្ម។

## ទិដ្ឋភាពទូទៅ៖ គោលការណ៍ណែនាំស្តីពីភាពធន់របស់អាជីវកម្មសម្រាប់រោងចក្រកាត់ដេរ

គោលការណ៍ណែនាំនេះរួមមានបញ្ជីផ្ទៀងផ្ទាត់ និងគំរូ

**គោលការណ៍ណែនាំនេះផ្តោតលើ៖**

- ការណែនាំលើប្រធានបទទាក់ទងនឹងរោងចក្រកាត់ដេរដែលចង់កសាងភាពធន់របស់អាជីវកម្ម។
- អនុសាសន៍ និងការណែនាំជាជំហាន ៗ សម្រាប់អ្នកគ្រប់គ្រងរោងចក្រកាត់ដេរ។
- ប្រធានបទរួមមាន៖ ការគ្រប់គ្រងលំហូរសាច់ប្រាក់ ការកាត់បន្ថយចំណាយ ការស្វែងរកប្រភពចំណូលផ្សេងទៀត ការធ្វើទំនាក់ទំនងជាមួយកម្មកររបស់អ្នក ការបង្កើតវត្តមាននៅលើអ៊ីនធឺណិត និងរៀបចំរោងចក្ររបស់អ្នកឱ្យមានសុវត្ថិភាព និងប្រសិទ្ធភាព។
- មានជាភាសា៖ បេងហ្គាលី ចិន អង់គ្លេស ខ្មែរ និងថៃ ។

## ការរីករាលដាលនៃជំងឺកូវីដ-១៩ និងរោងចក្រកាត់ដេរសម្លៀកបំពាក់នៅទ្វីបអាស៊ី

ឧស្សាហកម្មកាត់ដេរនៅទ្វីបអាស៊ីកំពុងប្រឈមនឹងផលប៉ះពាល់ធ្ងន់ធ្ងរពីការរីករាលដាលនៃជំងឺកូវីដ-១៩។ ដើម្បីកាត់បន្ថយផលប៉ះពាល់នេះ រោងចក្រកាត់ដេរត្រូវបង្កើនភាពធន់ និងរៀបចំខ្លួនសម្រាប់ផលប៉ះពាល់រយៈពេលវែងលើអាជីវកម្មរបស់ពួកគេ។ ឆ្លើយតបទៅនឹងតំរូវការបន្ទាន់នៃឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ អង្គការអន្តរជាតិខាងការងារបានបង្កើតគោលការណ៍ណែនាំចំនួន ៦ សម្រាប់អ្នកគ្រប់គ្រងរោងចក្រកាត់ដេរដោះស្រាយវិបត្តិនៃជំងឺកូវីដ-១៩ នេះ។



## គោលការណ៍ណែនាំចំនួន ៦ សម្រាប់រោងចក្រកាត់ដេរ

ជាមួយអនុសាសន៍សាមញ្ញៗ និងងាយអនុវត្ត ព្រមទាំងបញ្ជីផ្ទៀងផ្ទាត់ និងគំរូបន្ថែម គោលការណ៍ណែនាំទាំងនេះជួយរោងចក្រឱ្យធ្វើសកម្មភាពដើម្បីកែបង្កើនភាពធន់របស់ពួកគេ។ គោលការណ៍ណែនាំនេះត្រូវបានរៀបចំឡើងជាចម្បងសម្រាប់រោងចក្រកម្រិតទីពីរ និងរោងចក្រអនុវត្តកិច្ចសន្យាបន្ត

បច្ចុប្បន្ន មានគោលការណ៍ណែនាំចំនួន ៦ ដូចខាងក្រោម៖

**ការគ្រប់គ្រងលំហូរសាច់ប្រាក់របស់អ្នក ៖**
ពិនិត្យតាមដានលំហូរសាច់ប្រាក់របស់រោងចក្រអ្នក ដើម្បីដោះស្រាយបញ្ហាសម្រាប់រោងចក្ររបស់អ្នកឱ្យបានប្រសើរក្នុងអំឡុងពេលនៃវិបត្តិនេះ។

## បង្កើតឡើងជាចម្បងសម្រាប់រោងចក្រកម្រិតទីពីរ និងរោងចក្រអនុវត្តកិច្ចសន្យាបន្ត

**ការកាត់បន្ថយចំណាយ៖**
កាត់បន្ថយចំណាយដើម្បីសម្រួលដល់សន្ទនិយភាពហិរញ្ញវត្ថុ និងសម្ពាធលំហូរសាច់ប្រាក់លើប្រតិបត្តិការរោងចក្ររបស់អ្នក។

**ស្វែងរកប្រភពចំណូលផ្សេងទៀត៖**
កំណត់ប្រភពចំណូលថ្មីៗដើម្បីធានាថារោងចក្ររបស់អ្នកអាចជន្នះជំងឺរាតត្បាតនេះបាន។

**ការធ្វើអាជីវកម្មលើអ៊ីនធឺណិត៖ បង្កើតវត្តមានតាមអ៊ិនធរណេតៈ**
បង្កើតវត្តមានអាជីវកម្មនៅលើអ៊ីនធឺណិតដើម្បីផ្សព្វផ្សាយរោងចក្ររបស់អ្នក និងជួយសម្រួលដល់ការទំនាក់ទំនងជាមួយអ្នកទិញ។

**ការរៀបចំរោងចក្រដើម្បីប្រតិបត្តិការប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាពជាងមុន៖**
រៀបចំរោងចក្ររបស់អ្នកឡើងវិញដើម្បីផ្តល់នូវវិធានការដែលមានសុវត្ថិភាពល្អប្រសើរ និងបង្កើនប្រសិទ្ធភាពប្រតិបត្តិការរបស់ខ្លួន ។

**ការធ្វើទំនាក់ទំនងជាមួយកម្មកររបស់អ្នក៖** រក្សាទំនាក់ទំនងខាងក្នុងល្អ សម្រាប់បរិយាកាសរោងចក្រដែលឆ្លើយតបបានឆាប់រហ័ស និងផលិតភាពប្រសើរជាងមុនក្នុងអំឡុងពេលនៃវិបត្តិនេះ ។

យើងសូមណែនាំឱ្យរោងចក្រអានគោលការណ៍ណែនាំទាំងនេះតាមលំដាប់លំដោយខាងលើ។ គោលការណ៍ណែនាំទាំងនេះនឹងមានជាភាសាបេងហ្គាលី ចិន អង់គ្លេស ខ្មែរ និងថៃ។

**ការបដិសេធទំនួលខុសត្រូវ៖** មុននឹងចាប់ផ្តើមប្រតិបត្តិការឡើងវិញ វាជាការសំខាន់ណាស់ដែលអ្នកគ្រប់គ្រងរោងចក្រធានាថាកម្មករអាចវិលត្រឡប់ទៅធ្វើការវិញដោយសុវត្ថិភាព។ សម្រាប់ការណែនាំបន្ថែមស្តីពីប្រធានបទនេះ រោងចក្រអាចរកមើលឯកសាររបស់អង្គការអន្តរជាតិខាងការងារដូចខាងក្រោម៖

- <u>គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងកូវីដ-១៩ សម្រាប់រោងចក្រនៅប្រទេសបង់ក្លាដែស</u>

គោលការណ៍ណែនាំទាំងនេះត្រូវបានរៀបចំឡើងដោយនាយកដ្ឋានសហគ្រាសរបស់អង្គការ ILO សម្រាប់ **គម្រោងការងារសមរម្យនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់វិស័យកាត់ដេរនៅអាស៊ី** ដែលផ្តល់មូលនិធិដោយរដ្ឋាភិបាលស៊ុយអែត។

សម្រាប់ឯកសារ ឬធនធានផ្សេងៗទៀតដើម្បីជួយអ្នកដោះស្រាយស្ថានភាពក្នុងអំឡុងពេលនៃការរាតត្បាតនៃជំងឺកូវីដ-១៩ សូមចូលទៅកាន់៖

- ilo.org/covid19

**ក្រុមការងារគាំទ្របច្ចេកទេសគម្រោងការងារសមរម្យ**
**សម្រាប់តំបន់អាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិក**
អគារអង្គការសហប្រជាជាតិ ជាន់ទី ១0 ផ្លូវ Rajdamnern Nok
ទីក្រុងបាងកក ១0២00 ប្រទេសថៃ
ទូរស័ព្ទលេខ៖ ៦៦២ ២៨៨ ១២៣៤ ទូរសារ៖ ៦៦២ ២៨៨ ៣0៥៨
អ៊ីម៉ែល៖ BANGKOK@ilo.org